# អេស៊ីលីដា ត្រេននីង សេនធ័រ
# ACLEDA Training Center Ltd.

**ការិយាល័យកណ្តាល**

លេខ : អត្រស ១៨១៣ /១៤

**អគ្គនាយក អេស៊ីលីដា ត្រេននីង សេនធ័រ**

**គោរពជូន**

**នាយក-នាយិកា ធនាគារ អេស៊ីលីដា ភីអិលស៊ី គ្រប់សាខារាជធានី-ខេត្ត-ក្រុង**

**និងសាខាស្រុកកម្រិត " ក "**

**កម្មវត្ថុ : វគ្គបំពាក់បំប៉នការងារទីផ្សារ**

**យោង** : - សេចក្តីសម្រេចលេខ អត្រស ០៩៧/១៤ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៤ ស្តីពីការដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវគោលការណ៍ប្រតិបត្តិហ្វឹកហ្វឺន និងអភិវឌ្ឍន៍ធនធានមនុស្ស។

- អនុស្សរណៈនៃការយោគយល់គ្នាស្តីពី កិច្ចសហប្រតិបត្តិការ និងគាំទ្រ លើសេវាហ្វឹកហ្វឺនផ្ទៃក្នុងកម្មករនិយោជិត ធនាគារ អេស៊ីលីដា ភីអិលស៊ី រវាង ធនាគារ អេស៊ីលីដា ភីអិលស៊ី និង អេស៊ីលីដា ត្រេននីង សេនធ័រ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៣ និងការធ្វើវិសោធនកម្ម ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៣ ។
- ផែនការហ្វឹកហ្វឺនប្រចាំឆ្នាំ ២០១៤ ។
- លិខិតលេខ កធម ២២៧៣/១៤ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៤ ស្តីពីតម្រូវការរៀបចំបើកវគ្គបំពាក់បំប៉នការងារទីផ្សារ ។

តបតាមកម្មវត្ថុ និងយោងខាងលើ អេស៊ីលីដា ត្រេននីង សេនធ័រ នឹងមានរៀបចំបើកវគ្គបំពាក់បំប៉ន ដល់**ប្រធានផ្នែកទីផ្សារ និងប្រធានផ្នែកសាជីវកម្មអន្តរជាតិនៃនាយកដ្ឋានប្រតិបត្តិការនិងប្រធានភ្នាក់ងារទីផ្សារ ធនាគារ អេស៊ីលីដា ភីអិលស៊ី គ្រប់សាខារាជធានីខេត្ត-ក្រុង និងសាខាស្រុកកម្រិត " ក "** ដែលនឹងប្រព្រឹត្តទៅជា **ពីរវគ្គ ៖**

**<u>វគ្គទី១</u> : ថ្ងៃទី ១៨ ដល់ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៤**

**<u>វគ្គទី២</u> : ថ្ងៃទី ០១ ដល់ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៤**

នៅ**អេស៊ីលីដា ត្រេននីង សេនធ័រ ជាន់ទី៣ បន្ទប់ប្រាសាទអង្គរវត្ត** ដូចមានកាលវិភាគ និងបញ្ជីរាយនាមសាខា ជូនភ្ជាប់មកជាមួយ ។

អាស្រ័យហេតុនេះ សូមលោកនាយក-នាយិកា មេត្តាចាត់បញ្ជូនកម្មករនិយោជិត ដែលមានមុខតំណែងដូចខាងលើឲ្យចូលរួមក្នុងវគ្គបំពាក់បំប៉នតាមកាលបរិច្ឆេទ និងទីកន្លែងដូចបានជម្រាបជូន។

សូមលោកនាយក-នាយិកា ទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ភ្នំពេញ, ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៤

**ជ, អគ្គនាយក**

**នាយិកាការិយាល័យសិក្សា និងកិច្ចការនិស្សិតស្ត្រី**

**<u>ជូនភ្ជាប់មកជាមួយ</u>**

- កាលវិភាគវគ្គបំពាក់បំប៉ន
- បញ្ជីរាយនាមសាខាដែលត្រូវចូលរួម

**<u>ចម្លងជូន</u>**

- នាយិកាប្រតិបត្តិទីផ្សារ
- នាយកប្រតិបត្តិអភិវឌ្ឍន៍ផលិតផល
- នាយកប្រតិបត្តិហិរញ្ញប្បទានពាណិជ្ជកម្ម
- នាយកប្រតិបត្តិប្រតិបត្តិការ
- នាយិកាការិយាល័យគ្រប់គ្រងប័ណ្ណអេឡិចត្រូនិក
- នាយិកាការិយាល័យទំនាក់ទំនងអតិថិជន
- នាយកការិយាល័យប្រតិបត្តិ
- នាយកការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍន៍
- នាយកការិយាល័យទំនាក់ទំនងសាធារណៈ
- នាយកការិយាល័យគ្រប់គ្រងហានិភ័យ
- នាយកគ្រប់ការិយាល័យសវនកម្ម
- ជំនួយការនាយិកាការិយាល័យធនធានមនុស្ស
  " **ដើម្បីជូនជ្រាបជាព័ត៌មាន** "
- ឯកសារ-កាលប្បវត្តិ

This is an electronic letter sent by Sovanny Buntay